Australian Government
Department of Home Affairs

# សេចក្តីណែនាំសម្រាប់អតិថិជន – ភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់

វាជាការល្មើសច្បាប់ ប្រសិនបើបុគ្គលណាម្នាក់ដែលហ៊ានផ្តល់យោបល់ ឬ រៀបចំសំណុំរឿងអន្តោប្រវេសន៍នៅក្នុងប្រទេសអូស្ត្រាលីដោយមិនមែនជា ភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់ (registered migration agent) ឬ មេធាវី (lawyer) ឬ បុគ្គលដែលជាករណីលើកលែង (exempt persons) បុគ្គលទាំងនោះនឹងត្រូវទទួលទោសព្រហ្មទណ្ឌតាមផ្លូវច្បាប់។ ប្រសិនជាមានបុគ្គលណាម្នាក់ដែលបានផ្តល់យោបល់ ឬ រៀបចំសំណុំរឿងអន្តោប្រវេសន៍នៅក្នុងប្រទេសអូស្ត្រាលីដែលមិនបានចែងដូចខាងលើ អ្នកគួរតែរាយការណ៍ឈ្មោះបុគ្គលនោះមកកាន់ Border Watch Online Report នៅលើគេហទំព័ររបស់ Department of Home Affairs ។ ទោះបីជាបុគ្គលណាក៏ដោយដែលជួយរៀបចំសំណុំរឿងអន្តោប្រវេសន៍ឱ្យលោកអ្នក បុគ្គលទាំងនោះមិនអាចធានាឱ្យលោកអ្នកថានឹងបានទិដ្ឋាការ (visa) ឡើយ។

---

## ភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់

ភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់ (registered migration agents) ត្រូវតែមានស្តង់ដារវិជ្ជាជីវៈត្រឹមត្រូវ ធ្វើការគោរពតាមក្រមប្រតិបត្តិ (Code of Conduct) និងត្រូវបន្តសិក្សានូវចំណេះដឹងថ្មីៗស្តីអំពីច្បាប់ និងនិតិវិធីនៃការធ្វើអន្តោប្រវេសន៍។

គ្រប់ភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់ទាំងអស់មានលេខកូដពិសេសមួយដែលហៅថា Migration Agents Registration Number (MARN)។ លោកអ្នកអាចពិនិត្យមើលថាបុគ្គលម្នាក់នោះជាភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់ ឬ អត់តាមរយៈ OMARA នៅលើគេហទំព័រ www.mara.gov.au។

ការិយាល័យអាជ្ញាធរចុះឈ្មោះភ្នាក់ងារអន្តោប្រវេសន៍ (The **Office of the Migration Agents Registration Authority (OMARA)**) គឺជាផ្នែកមួយនៃ Department of Home Affairs និងជាស្ថាប័នបទប្បញ្ញត្តិសម្រាប់ភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់ដែលបានចុះឈ្មោះនៅក្នុងប្រទេសអូស្ត្រាលី។

ស្ថាប័នបទប្បញ្ញត្តិ OMARA មានតួនាទី៖

- វាយតម្លៃ និងផ្តល់នូវសេចក្តីសម្រេចនៃការសុំចុះឈ្មោះដើម្បីធ្វើជាភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់នៅក្នុងប្រទេសអូស្ត្រាលី។
- តាមដានការអនុវត្ត របស់ភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់ ធ្វើការស៊ើបអង្កេតតបតាមបណ្តឹងនានា និងចាត់វិធានការដាក់ពិន័យក្នុងករណីចាំបាច់។

ស្ថាប័នបទប្បញ្ញត្តិ OMARA មិនអាចជួយលោកអ្នកបានទេ ប្រសិនបើរឿងទាំងនោះទាក់ទងទៅនឹងទិដ្ឋាការ ឬ ការរៀបចំសំណុំរឿងអន្តោប្រវេសន៍ ឬ បញ្ហាឱ្យភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់សងលុយមកឱ្យលោកអ្នកវិញឡើយ។

## ក្រមប្រតិបត្តិ (Code of Conduct)

ក្រមប្រតិបត្តិ (Code of Conduct) សម្រាប់ភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់ តម្រូវឱ្យភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់ត្រូវតែ៖

- និយាយដោយស្មោះត្រង់អំពីឱកាសរបស់លោកអ្នកក្នុងការទទួលបានទិដ្ឋាការ
- ផ្តល់យោបល់ដែលត្រឹមត្រូវស្របច្បាប់ និងបន្តប្រាប់លោកអ្នកអំពីដំណើរការនៃសំណុំរឿងរបស់លោកអ្នក រួមទាំងការផ្លាស់ប្តូរនានាដែលទាក់ទងទៅនឹងសំណុំរឿងរបស់លោកអ្នក
- ធ្វើសកម្មភាពស្របច្បាប់ រៀបចំសំណុំរឿងដែលមានផលប្រយោជន៍ដល់លោកអ្នក និងការពារសិទ្ធិឯកជនរបស់លោកអ្នក
- ប្រាប់លោកអ្នកជាមុនប្រសិនបើភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់រូបនោះមានផលប្រយោជន៍ខ្វាស់ជាមួយនឹងផលប្រយោជន៍របស់លោកអ្នក ហើយនឹងចាត់វិធានការដែលសមស្របតាមតែអាចធ្វើបាន
- ផ្តល់នូវសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរមុនចាប់ផ្តើមធ្វើការទៅលើសំណុំរឿងរបស់លោកអ្នក នៅក្នុងសេចក្តីសម្រេចនោះត្រូវមាន សេវាកម្មដែលលោកអ្នកនឹងទទួលបាន តម្លៃប៉ាន់ស្មាន និងថ្លៃសេវាកម្មដែលទាក់ទងផ្សេងៗទៀត
- រក្សាប្រាក់របស់លោកអ្នកនៅក្នុងគណនីដោយឡែក ប្រសិនបើលោកអ្នកសម្រេចចិត្តបង់លុយមុន

- ផ្តល់ឱ្យលោកអ្នកនូវវិក័យបត្រដែលរៀបរាប់អំពីសេវាកម្មទាំងឡាយដែលបានបំពេញជាក់ស្តែង និងតម្លៃដែលនៅសល់ត្រូវបង់
- រក្សាកំណត់ត្រាឱ្យបានត្រឹមត្រូវទាក់ទងទៅនឹងដំណើរការនៃសំណុំរឿងរបស់លោកអ្នក។

ដើម្បីអាននូវក្រមប្រតិបត្តិទាំងមូល លោកអ្នកអាចចូលទៅកាន់ Code of Conduct ដែលអាចស្វែងរកបាននៅក្នុងគេហទំព័ររបស់ OMARA ។

## មានបញ្ហាជាមួយនឹងភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់

ប្រសិនជាលោកអ្នកមានបញ្ហាជាមួយនឹងភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់ សូមលោកអ្នកព្យាយាមដោះស្រាយបញ្ហាទាំងនោះជាមួយនឹងភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់ជាមុនសិន។ ប្រសិនជាលោកអ្នកមិនអាចដោះស្រាយបញ្ហាទាំងអស់នោះបានទេ លោកអ្នកអាចទាក់ទងមកកាន់ ស្ថាប័នបទប្បញ្ញត្តិ OMARA ដើម្បីសុំជំនួយ។ លោកអ្នកអាចបំពេញពាក្យបណ្តឹង ដើម្បីប្តឹងភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់របស់លោកអ្នកតាមរយៈ complaint form ដែលអាចស្វែងរកបាននៅក្នុងគេហទំព័ររបស់ OMARA។

ការដាក់ពាក្យបណ្តឹងទៅលើភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់ នឹងមិនប៉ះពាល់ពាក្យសុំទិដ្ឋាការរបស់លោកអ្នក ឬធ្វើឱ្យលទ្ធផលនៃការបដិសេធមិនចេញទិដ្ឋាការក្នុងសំណុំរឿង ឬ ការលុបចោលទិដ្ឋាការមានការប្រែប្រួលឡើយ។

## មេធាវីច្បាប់ និងបុគ្គលដែលជាករណីលើកលែងនៅប្រទេសអូស្ត្រាលី

បុគ្គលមួយចំនួនដូចជា មេធាវីច្បាប់ និងបុគ្គលដែលជាករណីលើកលែង មិនតម្រូវឱ្យចុះឈ្មោះដើម្បីធ្វើជាភ្នាក់ងារអន្តោប្រវេសន៍ដែលបានចុះឈ្មោះស្របច្បាប់នៅក្នុងប្រទេសអូស្ត្រាលីនោះទេ។

មេធាវីច្បាប់នៅប្រទេសអូស្ត្រាលីត្រូវតែគោរពតាមក្រមសីលធម៌របស់មេធាវីដែលបានចែងក្នុងស្ថាប័នរបស់ពួកគេ។ ប្រសិនបើលោកអ្នកចង់ដាក់ពាក្យបណ្តឹងទាក់ទងនឹងមេធាវីច្បាប់របស់លោកអ្នក លោកអ្នកអាចអាន សេចក្តីណែនាំសម្រាប់អតិថិជនមេធាវី (Consumer guide – legal practitioners) ដែលអាចស្វែងរកបានតាមរយៈគេហទំព័ររបស់ Department of Home Affairs website។

បុគ្គលដែលជាករណីលើកលែង រួមមានសមាជិកក្រុមគ្រួសារជិតស្និទ្ធ និងអ្នកធានាដាក់ទិដ្ឋាការ (sponsors)។ ដើម្បីស្វែងរក តារាងរបស់បុគ្គលដែលជាករណីលើកលែង លោកអ្នកអាចចូលទៅកាន់ *Form 956 – Appointment of a registered migration agent, legal practitioner or exempt person*។ បុគ្គលដែលជាករណីលើកលែងមិនត្រូវគិតថ្លៃសេវាក្នុងការផ្តល់យោបល់ ឬ រៀបចំសំណុំរឿងអន្តោប្រវេសន៍ឡើយ។

## ការដកសិទ្ធិពីភ្នាក់ងារ

ប្រសិនជាលោកអ្នកចង់ដកសិទ្ធិពីភ្នាក់ងារអន្តោប្រវេសន៍របស់លោកអ្នក លោកអ្នកអាចបំពេញ *Form 956*.

## សេវាកម្មបកប្រែ

លោកអ្នកអាចនិយាយទៅកាន់អ្នកបកប្រែជាភាសាខ្មែរ តាមរយៈ អង្គភាពបកប្រែថ្នាក់ជាតិ (TIS National)

www.tisnational.gov.au ☎ 131 450 ខែកក្កដា ឆ្នាំ២០២១